ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ ២៤៥៥ ...អទប/សគ៣

# សេចក្តីជូនដំណឹង

គណៈកម្មការកណ្តាលរៀបចំការប្រឡង សូមជូនដំណឹងដល់បេក្ខជន-បេក្ខនារី ជាសិស្ស-និស្សិត ដែលបានដាក់ពាក្យចូលរួមប្រឡងប្រជែងចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ ២០១៧ នៅថ្ងៃអាទិត្យ ទី ២៣ ខែកក្កដា ឆ្នាំ២០១៧ ឲ្យបានជ្រាបថា បេក្ខជន-បេក្ខនារីទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យបានម៉ឺងម៉ាត់តាមបទប្បញ្ញត្តិសម្រាប់បេក្ខជនប្រឡងដែលមានភ្ជាប់ជាមួយពាក្យសុំចុះឈ្មោះប្រឡងសម្រាប់បេក្ខជន-បេក្ខនារីម្នាក់ៗ ពិសេសហាមដាច់ខាតៈ

- យកតាមខ្លួននូវកាបូប ឬ សម្ពាយ
- ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទដែលអាចផ្ទុកឯកសារបាន ចូលក្នុងបន្ទប់ប្រឡង។

**ក្នុងករណីមេប្រយោគ ឬ អនុរក្សឆែករកឃើញ បេក្ខជននឹងត្រូវបណ្តេញចេញពីបន្ទប់ប្រឡង។**

អាស្រ័យហេតុនេះ បេក្ខជន-បេក្ខនារី ដែលបានដាក់ពាក្យចូលរួមប្រឡងចូលបម្រើការងារក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ សម្រាប់ឆ្នាំ២០១៧ ជ្រាបជាព័ត៌មាន និងអនុវត្តជាដាច់ខាត់៕

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៧
អគ្គនាយក និងជាអនុប្រធាន
គណៈកម្មការកណ្តាលរៀបចំការប្រឡង

ប្រាក់ សំអឿន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ: ១៧២៣.រដប

# បទប្បញ្ញត្តិ
## សម្រាប់បេក្ខជនប្រឡងជ្រើសរើសបញ្ចូលក្នុង
## ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
## សម័យប្រឡង ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៧

ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងវិន័យនៅក្នុងពេលប្រឡងឲ្យប្រព្រឹត្តទៅបានល្អប្រសើរ បេក្ខជនត្រូវគោរពដាច់ខាតតាមបទប្បញ្ញត្តិនៃការប្រឡងដូចខាងក្រោម ៖

១. <u>ប្រការដែលបេក្ខជនត្រូវអនុវត្ត</u> :
- ត្រូវមកដល់មណ្ឌលប្រឡង មុនចាប់ផ្តើមដំណើរការប្រឡងរយៈពេល ១៥ នាទី
- ត្រូវស្លៀកសំលៀកបំពាក់សមរម្យ
- ត្រូវយកមកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតសំគាល់ខ្លួន
- ត្រូវយកមកជាមួយនូវបង្កាន់ដៃទទួលពាក្យប្រឡង
- ត្រូវអនុវត្តតាមការណែនាំរបស់មេប្រយោគ និងអនុរក្ស
- រក្សារបៀបរៀបរយនៅក្នុងពេលប្រឡង
- ត្រូវប្រើប៊ិចដែលមានទឹកពណ៌ខៀវ
- ក្នុងពេលប្រឡងត្រូវរក្សាការស្ងៀមស្ងាត់ ។

២. <u>ប្រការដែលបេក្ខជនមិនត្រូវអនុវត្ត</u> :
- មិនត្រូវលួចចម្លង ឬមានបំណងលួចចម្លង
- មិនត្រូវពិភាក្សា ឬចម្លងគ្នាឡើយ
- មិនត្រូវយកអាវុធជាតិផ្ទុះចូលក្នុងមណ្ឌលប្រឡងឡើយ
- ហាមយកតាម និងប្រើប្រាស់ទូរស័ព្ទ វិទ្យុទាក់ទងគ្រប់ប្រភេទ និងឧបករណ៍អេឡិចត្រូនិចគ្រប់ប្រភេទដែលអាចផ្ទុកឯកសារបាន ចូលក្នុងបន្ទប់ប្រឡង។ ក្នុងករណីមេប្រយោគ ឬ អនុរក្សដែករកឃើញ បេក្ខជននឹងត្រូវបណ្តេញចេញពីបន្ទប់ប្រឡង។
- មិនត្រូវឲ្យអ្នកដទៃប្រឡងជំនួស ឬសរសេរកិច្ចការជំនួសនៅលើសន្លឹកកិច្ចការរបស់ខ្លួន
- មិនត្រូវគូសសញ្ញាសំគាល់នៅលើសន្លឹកកិច្ចការ ហើយសន្លឹកកិច្ចការណាដែលរកឃើញថាមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ
- មិនត្រូវធ្វើសកម្មភាពណាដែលនាំឲ្យចលាចលក្នុងមណ្ឌលប្រឡង
- ហាមដាច់ខាតចំពោះការសេពគ្រឿងស្រវឹង និងជក់បារីនៅក្នុងបរិវេណមណ្ឌលប្រឡង ។

រាល់ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិខាងលើ បេក្ខជនត្រូវប្រឈមនឹងការបញ្ឈប់មិនឲ្យប្រឡង ហើយសន្លឹកកិច្ចការរបស់បេក្ខជននោះនឹងត្រូវបានពិន្ទុសូន្យ និងទទួលទណ្ឌកម្មវិន័យផ្សេងៗទៀតដែលត្រូវបានកំណត់ដោយគណៈកម្មការកណ្តាលរៀបចំការប្រឡង ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧
**អគ្គនាយក និងជា**
**អនុប្រធានគណៈកម្មការកណ្តាលរៀបចំការប្រឡង**

ប្រាក់ សំអឿន